# របៀបចូលយកកំណត់ត្រា ការចាក់វ៉ាក់សាំងរបស់អ្នក ដោយប្រើ My Vax Records

## ជំហានទី 1៖ ចូលទៅ My Vax Records

ចូលទៅ៖ myvaxrecords.mass.gov

រួចហើយចុច Find my vaccine record (រកកំណត់ត្រារបស់ខ្ញុំ) ដើម្បីចាប់ផ្តើម។




## ជំហានទី 2៖ បញ្ចូលព័ត៌មានរបស់អ្នក

ដើម្បីរកកំណត់ត្រារបស់អ្នក ប្រព័ន្ធត្រូវការព័ត៌មានខាងក្រោម៖

* នាមខ្លួន
* នាមត្រកូល
* លេខទូរស័ព្ទដៃ ឬអ៊ីមែល
* ខែថ្ងៃឆ្នាំកើត
* ភិនភេទ

*កំណត់៖ អ្នកនឹងត្រូវតែអាចមើលទូរស័ព្ទដៃ ឬអ៊ីមែល ដែលអ្នកបញ្ចូល ដើម្បីទទួលតំណ ទៅចូលយកកំណត់ត្រារបស់អ្នក។*

បន្ទាប់មក បង្កើត PIN (អត្តលេខផ្ទាល់ខ្លួន) មួយ មានលេខ 4 ខ្ទង់ ដែលអ្នកនឹងចាំបាន។ អ្នកនឹងត្រូវបានសូម ឲ្យបញ្ចូល PIN នេះជាសាថ្មី ដើម្បីចូលយកកំណត់ត្រារបស់អ្នក បើសិនបានរកឃើញត្រូវគ្នា។ PIN មិនអាចប្រើលេខមួយខ្ទង់ (ដូចជា 1111) ឬលេខជាលំដាប់គ្នា (ដូចជា 1234) បានឡើយ។

បន្ទាប់មក គូសប្រអប់ ដើម្បីបញ្ជាក់ថាអ្នកមិនមែនជា robot (រូបយន្ត) ទេ។

នៅទីបញ្ចប់ កាលណាព័ត៌មានរបស់អ្នក បានបញ្ចូលរួច និង PIN របស់អ្នក បានបង្កើតរួច ចុចពាក្យ Submit (បញ្ជូន)។




*កំណត់៖ ព័ត៌មាននៅក្នុងកំណត់ត្រា MIIS របស់អ្នក គឺត្រូវបានប្រមូលមកពី អ្នកផ្តល់ការថែទាំសុខភាពរបស់អ្នក។ បញ្ចូលព័ត៌មាន ដែលអ្នកបានឲ្យទៅ អ្នកផ្តល់ការថែទាំសុខភាពរបស់អ្នក ដើម្បីធ្វើឲ្យកម្រិតត្រូវគ្នា របស់អ្នកល្អប្រសើរឡើង។*

## ជំហានទី 3៖ សំណើរបស់អ្នកត្រូវបានទទួល

ទំព័របញ្ជាក់មួយ គឺត្រូវបានបង្ហាញ កាលណាសំណើរបស់អ្នក ត្រូវបានបញ្ជូនមកដោយជោគជ័យ។

MIIS នឹងស្វែងរក ព័ត៌មានដែលអ្នកបានបញ្ចូល។

បើសិនបានរកឃើញ មិនត្រូវគ្នាទេ ឬអ្នកត្រូវការចូលយកកំណត់ត្រាមួយទៀត សំរាប់មនុស្សក្នុងបន្ទុក អ្នកអាចនឹងសាកម្តងទៀត ដោយមានព័ត៌មានខុសគ្នា ដោយចុចតំណ Please fill out the form again (សូមបំពេញ ទំរង់បំពេញម្តងទៀត)។


An official website of the Commonwealth of Massachusetts Learn more
English
My Vax Records

Access My Vaccination Records

Your request has been received

Thank you. If we find a match, we'll send you a link to your vaccine record. If we don't find a match, you'll receive a message with instructions for trying your search again.

**Please Note:** If you don't receive a response within 24 hours, please try submitting again, and check that you've typed in your cell phone number or email correctly. If you have questions, please contact the location where you received your vaccination or call us at 2-1-1.

**Need to make another request?** Please fill out the form again.

Did you find the information you were looking for? *
Yes No

SEND FEEDBACK

## ជំហានទី 4៖ ការជំរាបដំណឹង

ការជំរាបដំណឹង នឹងត្រូវបានផ្ញើតាមរយៈសារពាក្យ ឬអ៊ីមែល អាស្រ័យលើរបៀបទាក់ទង អ្នកបានជ្រើស។ ឆែកមើលផ្នត់ស្បាម ឬវត្ថុបោះចោល បើសិនអ្នកមិនបានទទួលអ៊ីមែលទេ។ ទាក់ទងក្រុមហ៊ុនទូរស័ព្ទរបស់អ្នក បើសិនអ្នកមិនបានទទួលសារ។

### បានរកឃើញត្រូវគ្នា

បើសិនត្រូវបាន រកឃើញត្រូវគ្នា នៅក្នុង MIIS ការជំរាបដំណឹង នឹងមានតំណមួយ ដើម្បីមើលកំណត់ត្រារបស់អ្នក។ ចុចតំណនោះ ដើម្បីចូលយកកំណត់ត្រារបស់អ្នក។

តំណនោះ នឹងនៅតែសកម្មចំនួន 24 ម៉ោង។ បើសិនអ្នកមិនចូលយកកំណត់ត្រារបស់អ្នក ក្នុងពេលនោះទេ អ្នកនឹងត្រូវបញ្ជូនសាថ្មី នូវសំណើថ្មីមួយទៀត។




ពាក្យសារ


My Vax Records

Thank you for visiting https://MyVaxRecords.mass.gov. Use this link within 24 hours to view your vaccine record: https://stage.mip.casetivity.com/pages/Confirm?key=9kak2ajhgxkbu4ej7uwja8wxh

**Massachusetts Immunization Information System (MIIS)**

The goal of the MIIS is to provide health care providers and families with complete, secure immunization records.

**© 2021 Commonwealth of Massachusetts.**

**Massachusetts Department of Public Health | Immunization Division**

*MIIS Official Website*

Have questions about accessing your vaccination records?
Visit our website or call us at 2-1-1
M-Th: 8:30 AM to 6:00 PM
F: 8:30 AM to 5:00 PM
Sa-Su: 9:00 AM to 2:00 PM

### មិនបានរកឃើញត្រូវគ្នា

បើសិនមិនបានរកឃើញត្រូវគ្នា នៅក្នុង MIIS ទេ ការជំរាបដំណឹង នឹងមានតំណមួយ ឲ្យសាកម្តងទៀត ឬទៅផ្នែកជំនួយរបស់យើង សំរាប់ឱវាទពីរបៀប ចូលយកកំណត់ត្រារបស់អ្នក។




ពាក្យសារ


My Vax Records

Thank you for visiting https://MyVaxRecords.mass.gov. Unfortunately, the information you provided does not match information in our system. Please try again or contact your healthcare provider to confirm the information on your record in the MIIS is correct. Make sure the information you submit matches the information you gave when you got your vaccine, such as the spelling of your name.

**Massachusetts Immunization Information System (MIIS)**

The goal of the MIIS is to provide health care providers and families with complete, secure immunization records.

**© 2021 Commonwealth of Massachusetts.**

**Massachusetts Department of Public Health | Immunization Division**

*MIIS Official Website*

Have questions about accessing your vaccination records?
Visit our website or call us at 2-1-1
M-Th: 8:30 AM to 6:00 PM
F: 8:30 AM to 5:00 PM
Sa-Su: 9:00 AM to 2:00 PM

## ជំហានទី 5៖ ចូលយកកំណត់ត្រារបស់អ្នក

ដើម្បីបញ្ជាក់ ថាអ្នកគឺពិតជាមនុស្ស ដែលបានស្នើពីដើម ត្រូវបញ្ចូល លេខ PIN - 4 ខ្ទង់ ដែលអ្នកបានបង្កើត។

បន្ទាប់មក ចុច Submit (បញ្ជូន)។




## ជំហានទី 6៖ ប័ណ្ណសុខភាព MIIS COVID-19 SMART និង កំណត់ត្រារបស់អ្នក

### ប័ណ្ណសុខភាព COVID-19 SMART

កំណត់ត្រា MIIS របស់អ្នកមាន ប័ណ្ណសុខភាព COVID-19 SMART។ លេខកូដ QR នេះ អាចទាញយកបាន និងសន្សំទុក ក្នុងឧបករណ៍ចល័តរបស់អ្នក ហើយអាចចែកចាយបាន នៅពេល អ្នកចង់បង្ហាញភស្តុតាង នៃការចាក់ថ្នាំការពាររោគ COVID-19 របស់អ្នក។

ដើម្បីទាញយក ប័ណ្ណសុខភាពឈ្លាសវៃ ចុចលើ COVID-19 SMART Health Card។

* ទូរស័ព្ទ APPLE៖ ដោយមាន iOS 15 ឬខ្ពស់ជាង អ្នកអាចថត លេខកូដ QR ដើម្បីផ្ទុកព័ត៌មាន ចូលក្នុង Health App របស់អ្នក។

* ទូរស័ព្ទ ANDROID៖ អ្នកអាចសន្សំទុក កំណត់ត្រាវ៉ាក់សាំង របស់អ្នកទៅ Google Pay បើសិនអ្នកមាន Android កំណែ 5 និង Google Play Services កំណែ 21.18 ឬខ្ពស់ជាង។

* ម្យ៉ាងវិញទៀត អ្នកអាចថតរូបពេញ នៃកំណត់ត្រាវ៉ាក់សាំង និង ប័ណ្ណសុខភាព COVID-19 SMART របស់អ្នក ហើយសន្សំ វាទុក ក្នុងម៉ាស៊ីនថតរបស់អ្នក។

### ប្រវត្តិការចាក់ថ្នាំការពាររោគ

កំណត់ត្រា MIIS របស់អ្នក ក៏មានការចាក់ថ្នាំការពាររោគ ផ្សេងៗ ទៀតទាំងអស់ដែរ ដែលអ្នកបានទទួល ដែលបានរាយការណ៍ ទៅ MIIS ដោយអ្នកផ្តល់ការថែទាំសុខភាពរបស់អ្នក។ ចុច Print All Immunizations (ផ្តិតការចាក់ថ្នាំការពាររោគទាំងអស់) ដើម្បីផ្តិតយកសំណៅនៃប្រវត្តិការចាក់ថ្នាំការពាររោគ របស់អ្នក។



## ការរកបញ្ហា

### ចុះបើសិនកំណត់ត្រារបស់ខ្ញុំ រកមិនឃើញ?

អ្នកចាក់វ៉ាក់សាំងឲ្យអ្នក បញ្ជូនកំណត់ត្រាការចាក់វ៉ាក់សាំងរបស់អ្នក ទៅ MIIS ប៉ុន្តែគេអាចជាបានផ្តល់ព័ត៌មាន មិនសព្វគ្រប់។ ដូច្នេះហើយ វាទំនងជាយើងមានកំណត់ត្រារបស់អ្នក ប៉ុន្តែមិនមែនព័ត៌មានត្រឹមត្រូវរបស់អ្នក។

សំរាប់ជាឧទាហរណ៍៖
- លេខទូរស័ព្ទចល័ត ឬអាសយដ្ឋាន អ៊ីមែល មិនបានបញ្ចូល ឬមិនត្រូវគ្នា
- បានប្រកបឈ្មោះខុសគ្នា
- ខែថ្ងៃឆ្នាំកើត មិនត្រូវគ្នា

សាកបញ្ចូលព័ត៌មានរបស់អ្នកសាថ្មី ដោយមានអ៊ីមែល ឬលេខទូរស័ព្ទចល័ត មួយផ្សេងទៀត ដើម្បីរកកំណត់ត្រារបស់អ្នក។ បើសិននៅតែរកមិនឃើញកំណត់ត្រារបស់អ្នកទេ ទាក់ទងអ្នកផ្តល់សេវារបស់អ្នក ដើម្បីកែកំណត់ត្រា ការចាក់វ៉ាក់សាំងរបស់អ្នកឲ្យត្រឹមត្រូវ ឬស្នើសុំមើលកំណត់ត្រារបស់អ្នកឡើងវិញ ដោយបញ្ជូនទំរង់បំពេញ សំណើកំណត់ត្រាការចាក់ថ្នាំការពាររោគ (Immunization Record Request)។ អ្នកនឹងត្រូវបានជំរាបដំណឹង ពីការរកឃើញរបស់យើង និងចំណាត់ការដោះស្រាយ ក្នុងពេល 2 - 3 អាទិត្យ។

បើសិនអ្នក បានទទួលការចាក់វ៉ាក់សាំងរបស់អ្នក មកពីភ្នាក់ងារសហព័ន្ធ (ដូចជា ក្រសួងការពារជាតិ, សេវាសុខភាពឥណ្ឌាន ឬកិច្ចការអតីតយោធិន) អ្នកនឹងត្រូវទាក់ទងភ្នាក់ងារទាំងនោះ សំរាប់ជំនួយ ជាមួយកំណត់ត្រាការចាក់វ៉ាក់សាំងរបស់អ្នក។

### ចុះបើសិនកំណត់ត្រាវ៉ាក់សាំងរបស់ខ្ញុំ មិនត្រឹមត្រូវ?

បើសិនព័ត៌មាន នៅលើកំណត់ត្រាវ៉ាក់សាំងរបស់អ្នក មិនត្រឹមត្រូវទេ (ដូចជា បាត់ដូស, ខុសកាលបរិច្ឆេទ ឬម៉ាកមិនត្រឹមត្រូវ) អ្នកអាចនឹងត្រូវកែតម្រូវ ឬកែប្រែកំណត់ត្រា ការចាក់ថ្នាំការពាររោគរបស់អ្នក។ អ្នកអាចទាក់ទង អ្នកផ្តល់ការថែទាំសុខភាពរបស់អ្នក ដើម្បីកែប្រែកំណត់ត្រារបស់អ្នក ឬបញ្ជូន Electronic Amendment Form (ទំរង់បំពេញការកែប្រែអេឡិកត្រូនិក)។ អ្នកនឹងត្រូវបានជំរាបដំណឹង ពីការរកឃើញរបស់យើង និងចំណាត់ការដោះស្រាយ ក្នុងពេល 2 - 3 អាទិត្យ។

### អ្នកផ្តល់ការថែទាំសុខភាពរបស់ខ្ញុំ បានកែប្រែកំណត់ត្រារបស់ខ្ញុំ ប៉ុន្តែខ្ញុំនៅតែមិនអាចចូលយក កំណត់ត្រារបស់ខ្ញុំដដែល ឬខ្ញុំមិនឃើញការកែប្រែនៅលើកំណត់ត្រារបស់ខ្ញុំ។

កាលណាអ្នកផ្តល់សេវា បញ្ជូនការកែប្រែ វានឹងប្រើពេល 24 - 48 ម៉ោង សំរាប់ការកែប្រែ ទើបអាចមើលឃើញកំណត់ត្រារបស់អ្នក។ បើសិនការកែប្រែត្រូវបានធ្វើចំពោះវ៉ាក់សាំង COVID-19 របស់អ្នក នោះអ្នកនឹងត្រូវចូលយក ប័ណ្ណសុខភាព SMART ដែលបានកែប្រែ តាមរយៈជំរតាល់ 24 - 48 ម៉ោង បន្ទាប់ពីអ្នកផ្តល់ការថែទាំសុខភាពរបស់អ្នក បានបញ្ជូនការកែប្រែ។

## របៀបទាក់ទងយើង

### តើនៅតែមានសំណួរទៀត អំពីការចូលយក កំណត់ត្រាការចាក់វ៉ាក់សាំងរបស់អ្នកឬ?

សំណួរដែលចោទសួរញឹកញាប់ អំពី My Vax Records

ហៅមកយើង លេខ 2 - 1 -1
ច័ន្ទ - ព្រហស្បតិ៍ 8: 30 ព្រឹក 6: 00 ល្ងាច សុក្រ៖ 8: 30 ព្រឹក 5: 00 ល្ងាច
សៅរ៍ - អាទិត្យ៖ 9: 00 ព្រឹក 2: 00 រសៀល

ផ្ញើអ៊ីមែលមកយើង តាម៖ MyVaxRecords@mass.gov